# ក្របខណ្ឌ Warsaw សម្រាប់ការអនុវត្តរេដបូក ( REDD+ )



# តើតម្រូវការអ្វីខ្លះ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីទទួល បានការទូទាត់ផ្អែកលើលទ្ធផល ក្នុងការអវត្តរេដបូក ?

- កិច្ចប្រជុំប្រទេសជាភាគី លើកទី ១៩ នៃក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ (UNFCCC)-COP19th រៀបចំនៅទីក្រុង Warsaw, Poland - អនុម័យ លើក្របខណ្ឌ 'Warsaw Framework for REDD+.







យន្តការសម្របសម្រួលថ្នាក់ជាតិ
យុទ្ធសាស្ត្រ ឬផែនការ
សកម្មភាពជាតិ (NRS)
ប្រព័ន្ធត្រួតពិនិត្យព្រៃឈើ
ជាតិ (NFMS)
ប្រព័ន្ធព័ត៌មានធានាសុវត្ថិ
ភាពរេដបូក (SIS)
កម្រិតបំភាយយោង
ព្រៃឈើ (FREL/REL)

# សកម្មភាពទាំងប្រាំរបស់រេដបូក



ការបាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ



ការបាត់បន្ថយការបំភាយឧស្ម័នពីរេចរឹលព្រៃឈើ



ការអភិរក្សការបូនស្តុកនៅព្រៃឈើ



ការគ្រប់គ្រងព្រៃឈើប្រកដោយនិរន្តរភាព



បង្កើនបរិមាណបូនស្តុកនៅក្នុងព្រៃឈើ

# ក្របខ័ណ្ឌ និងប្រព័ន្ធព័ត៌មានស្តីពី ការធានាសុវត្ថិភាពរេដបូក (SIS)





# សេចក្តីសម្រេចសំខាន់ៗរបស់UNFCCC ស្តីពីប្រព័ន្ធធានាសុវត្ថិភាព

- ប្រព័ន្ធធានាសុវត្ថិភាព Cancun (សេចក្តីសម្រេច 1/CP.16)
- សេចក្តីណែនាំ Durban (សេចក្តីសម្រេច 12/CP.17)
- ក្របខណ្ឌការងារ Warsaw (សេចក្តីសម្រេច 12/CP.19)



# កិច្ចព្រមព្រៀង Cancun (សេចក្តីសម្រេចចិត្ត១/ CP.១៦)

ពេលដែលដំណើរការសកម្មភាពបានយោងទៅក្នុងកថាខ័ណ្ឌ៧០ ការធានាសុវត្ថិភាពដូចខាងក្រោមនេះគួរតែត្រូវបានលើកកម្ពស់:

ក. បំពេញបន្ថែម ឬស្របទៅនឹង គោលបំណងកម្មវិធីព្រៃឈើជាតិ និងអនុសញ្ញាអន្តរជាតិ

ខ. រចនាសម្ព័ន្ធអភិបាលកិច្ចមានតម្លាភាព និងមានប្រសិទ្ធិភាពដែលគិតពីច្បាប់ និងអធិបតេយ្យភាពជាតិ

គ. គោរពចំពោះចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន



# កច្ចព្រមព្រៀង Cancun (សេចក្តសម្រេចចិត្ត១/ CP.១៦)

ឃ. ការចូលរួមពេញលេញនិងមានប្រសិទ្ធិភាពរបស់ស្ថាប័នពាក់ព័ន្ធជាពិសេសជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន

ង. ស្របជាមួយនឹងការអភិរក្សព្រៃធម្មជាតិ និងភាពសម្បូរបែបជីវសាស្ត្រ

ច. សកម្មភាពដើម្បីដោះស្រាយហានិភ័យនៃការត្រឡប់ថយក្រោយ

ឆ. សកម្មភាពដើម្បីកាត់បន្ថយ ការផ្លាស់ទីរបស់ការបំភាយឧស្ម័ន



# គោលបំណងសំខាន់ៗនៃប្រព័ន្ធធានាសុវត្ថិភាពរេដបូក

នៅកម្រិតអប្បរមា

- កំណត់ហានិភ័យអវិជ្ជមាននៃសកម្មភាពរេដបូក
- កំណត់វិធានការប្រតិបត្តិការ ដើម្បីបញ្ចៀស ឬ កាត់បន្ថយហានិភ័យអវិជ្ជមានឲ្យតូចបំផុត។

ប៉ុន្តែថែមទាំង,

- ជួយឲ្យរេដបូកអាចផ្តល់នូវពហុប្រយោជន៍ដល់សង្គម និងបរិស្ថាន
- ផ្តល់ឲ្យរដ្ឋាភិបាលនូវគោលការណ៍ណែនាំ ដើម្បីកំណត់ក្របខណ្ឌការងារកម្មវិធីជាតិ ដែលរួមបញ្ចូលនូវការគិតគូរពីបញ្ហាសង្គម និងបរិស្ថាន និងធានាថារេដបូក នឹងរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។



## ការរៀបចំប្រព័ន្ធព័ត៌មានស្ដីពីការធានាសុវត្ថិភាព (SIS)

- សេចក្ដីសម្រេចរបស់ UNFCCC លើកឡើងថា រដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ ត្រូវបង្កើតប្រព័ន្ធមួយ ដើម្បីផ្ដល់ព័ត៌មានអំពីរបៀបដែលការធានាសុវត្ថិភាពរេដបូក ត្រូវបានធ្វើឡើង និងគោរព នៅក្នុងការអនុវត្តសកម្មភាពរេដបូកទាំងមូល។
- ដោយធ្វើការពិចារណាលើសេចក្ដីសម្រេចទាំងនេះ ប្រទេសកម្ពុជាប្រើប្រាស់អភិក្រម ៣ ជំហាន ដើម្បីបង្កើតប្រព័ន្ធព័ត៌មានស្ដីពីការធានាសុវត្ថិភាពរបស់ខ្លួនដូចជា៖

1. ការបង្កើតសូចនាករ ផ្អែកទៅតាមសូចនាករ ដែលត្រូវបានប្រើប្រាស់នៅក្នុងគោលនយោបាយ និងវិធានការដែលមានស្រាប់
2. ការជ្រើសរើសវិធីសាស្ត្រសម្រាប់ប្រមូល និងវិភាគទិន្នន័យ និង
3. ការកំណត់ពីការទទួលខុសត្រូវរបស់ស្ថាប័ន ក្នុងការផ្ដល់ព័ត៌មាន។



# ប្រព័ន្ធពត៌មានអំពីប្រព័ន្ធធានាសុវត្ថិភាព (SIS)

សេចក្តីណែនាំ Durban

- ប្រទេសកំពុងអភិវឌ្ឍគឺតម្រូវឲ្យផ្តល់នូវពត៌មានអំពីរបៀបដែលប្រព័ន្ធធានាសុវត្ថិភាព Cancun ត្រូវបានដោះស្រាយ និងគោរព។

ក្របខណ្ឌការងារ Warsaw

- ប្រព័ន្ធពត៌មានអំពីប្រព័ន្ធធានាសុវត្ថិភាព គឺជាលក្ខខណ្ឌមួយសម្រាប់ការទូទាត់ផ្អែកលើលទ្ធផល (សេចក្តីសម្រេច 9 (4)/ CP 19).

- ប្រទេសកំពុងអភិវឌ្ឍតម្រូវឲ្យផ្តល់ពត៌មានដល់ UNFCCC យ៉ាងទៀតទាត់ ដោយផ្អែកលើមូលដ្ឋាននៃការស្ម័គ្រចិត្ត។



# កម្រិតបំភាយយោងព្រៃឈើ

( FREL/REL )





## អ្វីទៅជា FREL/REL ?

*ជាគោល ដើម្បីវាស់វែង ស្តីពី ការអនុវត្តសកម្មភាពរេដបូក របស់ប្រទេសកំពុងអភិវឌ្ឍន៍ ( ចំនួនឧស្ម័នដែលនឹងកាត់បន្ថយ រឺស្រូបយក) នឹងត្រូវធ្វើការវាយតម្លៃ តាមរយៈប្រព័ន្ធវាស់វែង  រាយការណ៍  និង ធ្វើការផ្ទៀងផ្ទាត់ (MRV)*

ប្រទេសដែលអនុវត្តរេដបូកត្រូវរៀបចំ កម្រិតបំភាយយោង  និងត្រូវបានវាយតម្លៃដោយអង្គការសហប្រជានមុនឈានដល់ការទូទាត់ហឹរញ្ញប្បទានផ្អែកលើលទ្ធផល



# តើទិន្នន័យ ស្តីពី FREL/REL នឹងដាក់ជូន UNFCCC ដោយរបៀបណា?

- ប្រទេសដែលអនុវត្តរេបូក គឺ លើទឹកចិត្តអោយដាក់ជូននូវឯកសារ FREL/REL ដោយស្ម័គ្រចិត្ត
- FREL/REL ត្រូវបាបរៀបចំដោយដំហាន នឹងធ្វើអោយប្រសើរឡើងពីពេលមួយទៅមួយ
- ដាក់ជូននូវព័ត៌មានក្នុងការរៀបចំ FREL/REL ដោយផ្អែកលើ ស្ថានភាពប្រទេស
- នឹងឆ្លងកាត់ការវាយតម្លៃជាលក្ខណៈអន្តរជាតិ
- អាចរៀបចំ ក្នុងទម្រង់ជាថ្នាក់ក្រោមជាតិ តែក្នុងទ្រង់បណ្តោះអាសន្ន អាចពង្រីកទៅថ្នាក់ជាតិ




ការប៉ាន់ប្រមាណការការបំភាយឧស្ម័ន្ធពីការ
បាត់បង់ព្រៃឈើពីឆ្នាំ ២០០៥ ដល់ ២០២០
អត្រាការបំភាយ ឧស្ម័ន្ធ ពីការបាត់បង់ព្រៃឈើ
= ចំនួនឥណទានកាបូន (CO2 e)
ដោយការអនុវត្តរេដបូក REDD
រយះពេល
ឆ្នាំ2000
ឆ្នាំ2005
ឆ្នាំ2020
ការបំភាយឧស្ម័ន្ធពី
ការបាត់បង់ព្រៃឈើ
នៅអតីតកាល
រយះពេលអនុវត្តរេដបូក

# ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ

( NFMS )



## តើអ្វីជា ប្រព័ន្ធត្រួតពិនិត្យព្រៃឈើ National Forest Monitoring Systems ( NFMS ) ?

ជាឧបករណ៍ដែលប្រើប្រាស់សម្រាប់ប្រមូលព័ត៌មានពីការ**បំភាយឧស្ម័ន** និងបរិមាណឧស្ម័នដែល**បាន**ស្រូប ដែលនឹងត្រូវធ្វើការ **វាស់វែង** **រាយការណ៍** **និង** **ផ្ទៀងផ្ទាត់** ( MRV ) មុនពេលទទួលបានការទូទាត់សងផ្អែកលើលទ្ធផល



# តើអ្វីទៅជាតម្រូវការក្នុងការរៀបចំ ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ ?

- ត្រូវរៀបចំ NFMS ក្នុងគោលបំណងដើម្បី ធ្វើការត្រួត ពិនិត្យ និងរាយការណ៍ពីការអនុវត្តសកម្មភាពរេដបូក

- គួរតែមានលក្ខណៈច្បាស់លាស់ និងផ្តល់ព័ត៌មាន តម្លាភាព និង មានភាពស៊ីគ្នារៀងរាល់ពេល



# ចរិកលក្ខណៈរបស់ NFMS

- គួរតែរៀបចំឡើងដោយផ្អែកលើប្រព័ន្ធដែលមានស្រាប់
- គួរតែអាចធ្វើការវាយតម្លៃលើប្រភេទព្រៃផ្សេងៗគ្នា ដែលប្រទេសជាអ្នកកំណត់
- អាចបត់បែនបាន និងអាចធ្វើអោយប្រសើឡើងនាពេលខាងមុខ
- គួរអាចរួមបញ្ចូលទាំង ព័ត៌មានពីរូបភាពផ្កាយរណប និង សារពើភណ្ឌទីវាល
- ស្របតាមជំហាននៃការអនុវត្តរេដបូក
- រៀបចំអោយស្របតាម គោលការណ៍ណែនាំ IPCCC ដែលធ្វើបច្ចុប្បន្នភាពចុងក្រោយ











អរគុណ !